**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១១៤៧ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការបង្កើតក្រុមការងារគំរោងជាតិ និងក្រុមផ្តល់ប្រឹក្សាបច្ចេកទេសលើការងារស្វ័យប្រវត្តិកម្មគយ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រម នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស. ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស. រកម. ០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ. បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសំរេចលេខ២០០៥ សហវ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសំរួល និងបំពេញបន្ថែមលើគោលការណ៍គ្រប់គ្រងមន្ត្រីរាជការគយ និងរដ្ឋាករ

- បានឃើញប្រកាសលេខ៩២០ សហវ ប្រក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីចាត់ការគយ និងរដ្ឋាករ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង UNCTAD ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៦ ស្តីពីគំរោង ASYCUDA
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារគំរោងជាតិ(National Project Team )លើគំរោងស្វ័យប្រវត្តិកម្មគយ ASYCUDA ។

**ប្រការ ២** : ក្រុមការងារគំរោងជាតិមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. លោកបណ្ឌិត គុណ ញឹម | នាយករងទីចាត់ការគយ និងរដ្ឋាករ | ប្រធាន |
| ២. លោក គង់ តារា | អនុប្រធានទីស្នាក់ការគយ-រដ្ឋាករ | សមាជិក |
| ៣. លោក គង់ សុខផល្លាគុណ | ជំនួយការការិយាល័យគយ-រដ្ឋាករ | សមាជិក |
| ៤. លោក ផា អេងវើង | ជំនួយការការិយាល័យគយ-រដ្ឋាករ | សមាជិក |
| ៥. លោក រស់ ដារ៉ា | ជំនួយការការិយាល័យគយ-រដ្ឋាករ | សមាជិក |
| ៦. លោក ប៉ុល គីមសែន | ភ្នាក់ងារគយ-រដ្ឋាករ | សមាជិក |
| ៧. លោកបណ្ឌិត សង់ ស៊ីណាវិទ្យ | ភ្នាក់ងារគយ-រដ្ឋាករ | សមាជិក |

**ប្រការ ៣** : ក្រុមការងារនេះមានភារកិច្ចបំពេញរាល់ការងារទាំងអស់ ដែលពាក់ព័ន្ធនឹងការអនុវត្តគំរោងស្វ័យប្រវត្តិកម្មគយ ASYCUDA ។ ក្នុងដំណើរការនៃការអនុវត្តគំរោងនេះ ក្រុមការងារត្រូវសហការអោយបានល្អប្រសើរជាមួយអ្នកជំនាញការអន្តរជាតិ ។

**ប្រការ ៤** : បង្កើតក្រុមផ្តល់ប្រឹក្សាបច្ចេកទេស ( Technical Advisory Group ) ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. លោក សៀង ឈុនទ្រី | នាយករងទី១ | ប្រធាន |
| ២. លោកបណ្ឌិត ប៉ែន សំអាត | ប្រធានការិយាល័យលេខាធិការ និងជាប្រធានការិយាល័យវិវាទ និងច្បាប់ | សមាជិក |

| | | |
|---|---|---|
| ៣. លោក នួន ច័ន្ទរិទ្ធ | ប្រធានការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៤. លោក អ៊ុយ សារិន | ប្រធានការិយាល័យត្រួតពិនិត្យ | សមាជិក |
| ៥. លោក ជា ហាក់ | ប្រធានការិយាល័យនាំចេញ | សមាជិក |

**ប្រការ ៥** : ក្រុមផ្ដល់ប្រឹក្សាបច្ចេកទេសត្រូវជួយដល់ក្រុមការងារគំរោងជាតិនូវមតិ យោបល់ និង អនុសាសន៍នានាអំពីបច្ចេកទេសគយ និងការងារគយពាក់ព័ន្ធផ្សេងទៀត ដែលបំរើដល់ការ រៀបចំ និងអនុវត្តគំរោង ASYCUDA ។

**ប្រការ ៦** : ក្រុមការងារគំរោងជាតិត្រូវរៀបចំ និងកំណត់របបប្រជុំរបស់ខ្លួន ហើយមានសិទ្ធិអញ្ជើញមន្ត្រី ឬភ្នាក់ងារគយ-រដ្ឋាករ ឬអ្នកឯកទេសជំនាញមកបំភ្លឺ ឬពិគ្រោះយោបល់ក្នុងករណីចាំបាច់ ។

**ប្រការ ៧** : ក្នុងមួយត្រីមាសម្ដង ក្រុមការងារគំរោងជាតិ ត្រូវធ្វើរបាយការណ៍សរុបអំពីការងាររបស់ ខ្លួនជូនគណៈកម្មការដឹកនាំគំរោង និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៨** : ប្រកាស ឬសេចក្ដីសំរេចណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩** : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងសាមីខ្លួនត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពី ថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូន:</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ការិយាល័យធនាគារពិភពលោកប្រចាំនៅកម្ពុជា
  «ដើម្បីជូនជ្រាប»
- ដូចប្រការ៩ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ-ឯកសារ